POSTED BY ថុល អ៊ុន

At: http://buddhacakra.blogspot.com.au/2012/07/blog-post_7208.html

# គុណសម្បត្តិ និង គុណវិបត្តិ នៃអាចារ្យនៅក្នុងសង្គមខ្មែរ



Picture: May Ebihara

*សង្គមខ្មែរចាត់ទុកអាចារ្យជាមនុស្សសំខាន់ណាស់ ជាអ្នកមានតម្លៃថ្លៃថ្នូរ ជាបុគ្គលប្រកបដោយកិត្តិយស អាចនិយាយបានផងដែរថាជាមគ្គុទ្ទេសក៍ អ្នកនាំផ្លូវ ចង្អុលផ្លូវ ឲ្យសង្គមដើរឆ្ពោះទៅរកភាពសុខសាន្ត។ ក្នុងន័យនេះ អាចារ្យ ត្រូវមានចក្ខុវិស័យ មួយច្បាស់លាស់ ហើយលោកបានផ្សាភ្ជាប់ខ្លួននឹងព្រះពុទ្ធសាសនា ធ្វើដំណើរអបព្រះ ពុទ្ធសាសនា រក្សាលើកស្ទួយវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរ ឲ្យបានឋិតស្ថេរខ្ជាប់ខ្ជួន និង ថ្កុំថ្កើងរុងរឿង សក្តិសមជាជាតិ មួយដែលធ្លាប់មានអារ្យធម៌ចិញ្ចែងចិញ្ចាច នៅអាស៊ីអាគ្នេយ៍នេះ។*

## គុណសម្បត្តិរបស់អាចារ្យ

**ក- វិជ្ជាសម្បត្តិ** *អាចារ្យត្រូវមានចំណេះដឹងទាំងផ្លូវពុទ្ធចក្រនិងផ្លូវអាណាចក្រ គឺត្រូវតែជាអ្នកបានបួស បានរៀនចេះដឹង មានជាអាទិ៍រៀនអក្សរសាស្ត្រ, លេខនព្វន្ត, ច្បាប់អប់រំដំបូន្មានផ្សេងៗ, វិធីសមាទាននិច្ចសីល, រៀនវិជ្ជាភូមិសាស្ត្រ និងច្បាប់ប្រពៃណីទំនៀមទម្លាប់ ។ល។*

**ខ-អ្នកដឹកនាំល្អ** *អាចារ្យត្រូវមានសមត្ថភាពដឹកនាំអ្នកដទៃឲ្យចេះធ្វើកិច្ចក្នុងពិធីបុណ្យព្រះពុទ្ធសាសនាផង និងពិធីទំនៀមទម្លាប់ប្រពៃណីខ្មែរផង ។ អាចារ្យអ្នកដឹកនាំគេធ្វើបុណ្យកុសលផ្សេងៗ មិនត្រឹមតែចេះដឹង*

ក្នុងកិច្ចពិធីនីមួយៗប៉ុណ្ណោះទេ ប៉ុន្តែត្រូវឈ្លាសក្នុងពុទ្ធវិន័យផងទើបប្រសើបំផុត។ ឯពាក្យថាឈ្លាសក្នុងព្រះវិន័យនោះ គឺដឹងរបស់ដែលគួរឬរបស់ដែលមិនគួរ។

**គ- មានវោហារ** អាចារ្យត្រូវមានសម្តីវោហារប៉ិនប្រសប់ ប្រកបដោយវចីសុចរិតគឺ និយាយតែពាក្យពិត, និយាយពាក្យផ្អែមល្ហែមទន់ភ្លន់, និយាយតែពាក្យធ្វើឲ្យមានភាពសាមគ្គីគ្នា, និយាយតែពាក្យណាមានប្រយោជន៍។ អ្នកនិយាយល្អ គឺចេះនិយាយសម្របសម្រួលវែកញែករកហេតុផលឲ្យគេស្តាប់បាន, ចេះនិយាយជំទាស់ ឬ បដិសេធដោយមានហេតុផល ឬច្បាប់សំអាង, ចេះនិយាយផ្តល់យោបល់ ឬបង្ហាញគំនិតល្អៗដល់អ្នកស្តាប់, ចេះនិយាយលើកសរសើរឲ្យគេពេញចិត្ត ។




**ឃ-ត្រូវមានទំនាក់ទំនងល្អជាមួយនឹងពុទ្ធបរិស័ទ**
អាចារ្យត្រូវប្រតិបត្តិទៅតាមផ្លូវ កណ្តាលគឺវៀរចាកអំពើអគតិធម៌ទាំង៤ គឺ ឆន្ទាគតិ (លម្អៀងព្រោះសេចក្តីស្រឡាញ់), ទោសាគតិ (លម្អៀងព្រោះសេចក្តីខឹងក្រោធ), ភយាគតិ (លម្អៀង ព្រោះសេចក្តីភ័យខ្លាច), មោហាគតិ (លម្អៀង ព្រោះសេចក្តីមិនយល់ការណ៍, មិនដឹងខុសត្រូវ) ។

**ង- អ្នកស្មោះត្រង់និងមានកាយ វាចា ចិត្ត ល្អ** អាចារ្យគ្រប់រូបបើមានចំណេះវិជ្ជាហើយ ត្រូវមានសីលប្រព្រឹត្តឲ្យបានល្អត្រឹមត្រង់ផងដែរ។ ការឃោសនាអប់រំណែនាំពុទ្ធបរិស័ទឲ្យជឿបុណ្យបាប គុណទោស ធ្វើបុណ្យកុសលផ្សេងៗ គឺជាតួនាទីរបស់លោកអាចារ្យ ដូច្នេះលោកអាចារ្យមិនមែននិយាយឲ្យតែគេជឿ ឱ្យគេប្រព្រឹត្ត ហើយខ្លួនឯងមិនជឿមិនប្រព្រឹត្តនោះទេ។

នៅក្នុងសង្គមខ្មែរយើងតាំងពីបុរាណកាលរហូតមកដល់បច្ចុប្បន្នកាល តែងមានសាសនា ប្រពៃណី ទំនៀមទម្លាប់ ជាទីសក្ការៈនិងគោរពប្រតិបត្តិ ជាឃ្លាំងសម្រាប់អប់រំសីលធម៌សន្តានចិត្តកូនខ្មែរគ្រប់រូបឲ្យមានចរិយាមារយាទថ្លៃថ្នូរ ដឹងខុសត្រូវ បាបបុណ្យ គុណទោស សព្វបែបយ៉ាង ធ្វើឲ្យកូនខ្មែរបានស្គាល់ផ្លូវកសាងសន្តិភាព សាមគ្គីភាពនៅក្នុងសង្គមយ៉ាងប្រសើរបំផុត។




អ្នកចេះដឹងជ្រៅជ្រះប្រកបដោយសីលធម៌ ហើយបន្តការអប់រំល្អឲ្យដល់អ្នកឯទៀតនេះឯង លោកហៅថាអាចារ្យ។

## គុណវិបត្តិរបស់អាចារ្យ

គួរគប្បីជ្រាបថា វិបត្តិអាចារ្យ និងវិបត្តិព្រះពុទ្ធសាសនា គឺមានអត្ថន័យប្រហាក់ប្រហែលគ្នា។ ក្នុងន័យនេះយើងលើកបញ្ហាខ្លះដែលនាំឲ្យមានវិបត្តិអាចារ្យដូចតទៅ៖

**ក-កង្វះសមត្ថភាព** អាចារ្យពុំមានសមត្ថភាពបំពេញវិជ្ជាជីវៈរបស់ខ្លួនឲ្យបានពេញលេញ និងត្រឹមត្រូវដូចជាដឹកនាំធ្វើកម្មវិធីផ្សេងៗ ដោយស្មានៗ អត្តនោម័តិ ធ្វើត្រូវក៏មិនដឹង ធ្វើខុសក៏មិនដឹង ធ្វើទាំងប្រថុយប្រថានដោយមិនផ្អែកទៅលើក្បួនខ្នាតជាមូលដ្ឋាន។ អាចារ្យខ្លះខ្វះសីលធម៌ មានផឹកស្រា ឈ្លោះទាស់ទែងគ្នាជាមួយអ្នកស្រុក, លោភលន់កេងប្រវ័ញ្ច ចង់មានចង់បានហួសហេតុ បង្កជាវិវាទជម្លោះទំនាស់ បង្អាប់គ្នា ប្រជែងគ្នា ចង់ឈ្នះ ចង់ចាញ់គ្នា ដើម្បីដណ្តើមផលប្រយោជន៍ នាំឲ្យសាបសូន្យខ្លួនឯង ហើយមហាជនដកជំនឿទុកចិត្ត បែកបាក់គ្នា បាត់បង់សាមគ្គីភាពនៅក្នុងសហគមន៍។

**ខ-អសីលធម៌វិជ្ជាជីវៈ** ជាមួយនឹងពេលវេលា ផ្នត់គំនិតមនុស្សមានការវិវត្តិ ដោយងាកឃ្លាតចេញឆ្ងាយបន្តិចម្តងៗពីសច្ចៈ ខន្តី ផ្តោតទៅរកកិលេសតណ្ហាមានជាអាទិ៍ អភិជ្ឈា ឧបាទាន លោភៈ ទោសៈ មោហៈ ដែលជាមេបាបធម៌ នាំមនុស្សឲ្យលិចលង់ក្នុងសង្សារទុក្ខមិនចេះចប់។ បច្ចុប្បន្ននេះអាចារ្យ ឬគណៈអាចារ្យលែងសូវមានគុណធម៌ដូចអាចារ្យពីដើម ដូចបានពោលខាងលើនោះទៀតហើយ។ អាចារ្យក្នុងសម័យនេះ

ច្រើននាំគ្នាលៃច្នៃវិជ្ជាជីវៈរបស់ខ្លួនឲ្យទៅជាមុខរបរមួយយ៉ាងពេញបន្ទុក។ អាចារ្យខ្លះបង្គាប់ឲ្យម្ចាស់ដើមការផ្តល់នូវវត្ថុកស្តុការលុយកាក់តាមហាងឆេងដែលខ្លួនជាអ្នកកំណត់  ទម្លាក់តម្លៃខ្លួនឲ្យក្លាយទៅជាទំនិញ។ បើអាចារ្យក្លាយជាទំនិញគេតថ្លៃបាន នោះមិនយូរមិនឆាប់នឹងកើតមានវិបត្តិអាចារ្យ។

**គ-អសកម្មភាពរបស់អាចារ្យ**  កាលពីជំនាន់ដើម អាចារ្យមានតួនាទីសកម្ម គឺមានសិទ្ធិពេញលេញក្នុងការដឹកនាំធ្វើពិធីអ្វីៗ បានទៅតាមសមត្ថភាពនិងការចេះចាំរបស់គាត់ ព្រោះនៅក្នុងពិធីនីមួយៗ គ្មានអ្នកណាចេះដឹងជាងគាត់ឡើយ។ ប៉ុន្តែមកដល់សម័យនេះ លោកអាចារ្យត្រូវរណបនឹងសភាពការ (ជាពិសេសក្នុងពិធីមង្គលការ) សូមលើកឧទាហរណ៍ខ្លះៗមកបញ្ជាក់ ៖

- អ្នកថតបញ្ឈប់ដំណើរពិធីរបស់អាចារ្យ ដើម្បីថតយករូបឲ្យបានច្រើន។
- អាចារ្យត្រូវបង្ខំចិត្តជម្រុះចោលពិធីមួយចំនួន ដើម្បីតម្រូវតាមចិត្តអ្នកដើមការឲ្យសមស្របនឹងពេលវេលាអាពាហ៍ពិពាហ៍ដែលបង្រួញឲ្យនៅខ្លីតែមួយព្រឹក។
- នៅជនបទ លោកអាចារ្យត្រូវបានក្មេងៗយុវជនមករំខានរារាំងមិនឲ្យធ្វើពិធីផ្សេងៗក្នុងពេលយប់ ដូចរៀបផ្លែឈើ កាត់ស្លឹក បេះល័ក្ខ បុកល័ក្ខ ធ្វើធ្មេញបំពេញល័ក្ខ អង្គុយអង្គររាប ... ហើយឆក់យកមីក្រូទៅច្រៀងរាំលេងសប្បាយ ។ល។




## ផលវិបាកចំពោះអាចារ្យ

មានកត្តាជាច្រើនប៉ះពាល់ដល់អាចារ្យដូចជា៖

- **កត្តាមនុស្ស**

មហាជននៅក្នុងកន្លែងមួយចំនួនមានការរើសអើងប្រកាន់យ៉ាងមុតមាំមិនយកអាចារ្យដែលដឹកនាំធ្វើពិធីបុណ្យខ្មោចមកធ្វើជាអាចារ្យពិធីមង្គលការឡើយ ដោយគេជឿថា អាចារ្យបុណ្យខ្មោចជិតដាមដោយឧបទ្រពចង្រៃ នាំមកអពមង្គលដល់ពិធីមង្គលការ ដល់គូស្វាមីភរិយា។  អ្នកយល់ដូច្នោះ មិនសក្តិសមជាអ្នកកាន់ព្រះពុទ្ធសាសនាឡើយ ព្រោះមិនដឹងមិនយល់ពីត្រៃ

លក្ខណ៍ អនិច្ចំ ទុក្ខំ អនត្តា ជាមនុស្សពោរពេញដោយធម៌ប្រមាទ មិនស្គាល់អំពីដំណើររបស់ជីវិត ជាតិជរា ព្យាធិ មរណៈ ពិសេសមិនយល់ពីកុសលកម្ម និងអកុសលកម្ម។ គប្បីជ្រាបថា ធ្វើបុណ្យខ្មោចក៏ជាកុសលកម្ម ក៏ជាមង្គល គឺមង្គលដល់អ្នករស់និងដល់អ្នកស្លាប់។

**- កត្តាអប់រំ**

ដោយសង្គមកម្ពុជាយើងត្រូវរបបប្រល័យពូជសាសន៍ប៉ុលពត បំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងនូវធនធានអ្នកចេះដឹង ឯគម្ពីរក្បួនច្បាប់ទម្លាប់ក៏បាត់បង់ស្ទើរគ្មានសល់ ម្ល៉ោះហើយធនធានអាចារ្យនៅតិចតួចណាស់ អាចារ្យខ្លះក៏បានសិក្សារៀនសូត្រតាមក្បួនតម្រាបានច្រើន លោកអាចារ្យខ្លះសិក្សាបានតិច ខ្លះទៀតក៏មើលតាមសៀវភៅដោយខ្លួនឯង។ ដោយក្បួនច្បាប់ពុំសូវសម្បូរ ការអប់រំផ្សព្វផ្សាយនៅមានកំរិត ដូច្នេះហើយធ្វើឲ្យអាចារ្យទទួលផលវិបាកខ្លាំង ក្នុងការរក្សាប្រពៃណីទំនៀមទម្លាប់ខ្មែរយើងឲ្យបានល្អ។

**- កត្តាសង្គម**

ដោយសង្គមខ្មែរយើងអ្នកកាន់ព្រះពុទ្ធសាសនាស្ទើរតែ៩០ភាគរយ ប្រជាពលរដ្ឋខ្មែរចូលចិត្តធ្វើបុណ្យច្រើន ហើយប្រកាន់យកនូវទំនៀមទម្លាប់ល្អ គឺការតបស្នងសងគុណដល់អ្នកមានគុណមានមាតាបិតាជាដើម ម្ល៉ោះហើយលោកអាចារ្យទទួលការអញ្ជើញជាអធិបតីច្រើនកន្លែង ទទួលបុណ្យខ្លះ ទទួលមង្គលការខ្លះ ពិធីផ្សេងៗខ្លះ ... ហេតុនេះហើយលោកអាចារ្យខ្លះគាត់ធ្វើកាត់ខ្លីៗ ពុំបានត្រឹមត្រូវ ល្អសព្វគ្រប់ ព្រោះប្រញាប់ទៅកន្លែងមួយទៀត។ នេះជាផលវិបាកធ្វើឲ្យប្រពៃណីល្អរបស់យើងចេះតែបាត់ទៅបន្តិចម្តងៗ មិនយូរមិនឆាប់ក្បួនច្បាប់នេះនឹងសាបសូន្យព្រោះតែវិបត្តិអាចារ្យ។

**Khmer Story Lovers សូមអភ័យទោសដោយពុំដឹងឈ្មោះរបស់បណ្ឌិតដែលបានសរសេររៀបរៀងឯកសារនេះ**